## ឧបសម្ព័ន្ធទី ២ : គុណភាព និង ប្រសិទ្ធភាព : តារាងសកម្មភាពគោលនយោបាយនុងវាំងវិស័យ ២០០៤-០៨

| វិសាលភាពគោលនយោបាយ<br>និងយុទ្ធសាស្ត្រ | សកម្មភាព<br>( ត្រឹមចុងឆ្នាំ២០០៤ ) | សកម្មភាព<br>( ត្រឹមពាក់កណ្ដាលឆ្នាំ២០០៦ ) | សកម្មភាព<br>( ត្រឹមដើមឆ្នាំ២០០៨ ) |
|---|---|---|---|
| ក-បង្កើនបៀវត្សចំពោះសេវាកម្មអប់រំ និងផ្ដល់រង្វាន់លើកទឹកចិត្ត ដោយផ្សារភ្ជាប់ទៅនឹងការបំពេញការងារ | • ផែនការដែលបានឯកភាព ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងកម្មវិធីជាតិកំណែទំរង់រដ្ឋបាល (NPAR)ដើម្បីបង្កើនប្រាក់បៀវត្សរ៍/ប្រាក់ឧបត្ថម្ភផ្សេងៗដល់បុគ្គលិកបង្រៀន ដោយអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យនៃការបំពេញការងារ និងការទទួលខុសត្រូវ<br><br>• ផែនការសកម្មភាពសំរាប់ការពង្រាយគ្រូបង្រៀន និងការពង្រាយឡើងវិញបុគ្គលិកមិនបង្រៀន អោយទៅបង្រៀននៅតាមតំបន់ និងសាលាដែលខ្វះគ្រូ ។ | • ក្រសួងអប់រំ យុវជន និងកីឡា កម្មវិធីជាតិកំណែទំរង់រដ្ឋបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការពិនិត្យឡើងវិញរួមគ្នាលើប្រសិទ្ធភាពនៃកំនែទំរង់បៀវត្ស និងអនុមត័លើសកម្មភាពពិនិត្យតាមដាន<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៍ នៃយុទ្ធសាស្ត្រពង្រាយគ្រូ និងពង្រាយឡើងវិញបុគ្គលិកមិនបង្រៀន ដោយរួមទាំងការកែលំអគោលការណ៍ណែនាំ និងប្រាក់ឧបត្ថម្ភ ។ | • សិក្សាផលប៉ះពាល់ នៃកំនែទំរង់បៀវត្សមន្ត្រីអប់រំ ទៅលើគុណភាព និង ប្រសិទ្ធភាពសេវាអប់រំ ។ |
| ខ-បង្កើនស្វ័យភាពប្រតិបត្តិការ ក្នុងការប្រើប្រាស់ថវិកាដំណើរការសាលារៀន និងគ្រឹះស្ថានសិក្សា | • ពិនិត្យឡើងវិញលើបទពិសោធន៍ ដែលបានពីកម្មវិធីសកម្មភាពជាអាទិភាពដែលផ្តោតទៅលើគុណភាព ជាពិសេសថវិកាដំណើរការសាលារៀន<br><br>• កែលំអគោលការណ៍ណែនាំ និងអាំងឌីកាទ័របំពេញការងារ សំរាប់ការប្រើប្រាស់ថវិកាដំណើរការ ដោយគិតដល់ការបង្កើនគុណភាព ។ | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៃប្រសិទ្ធភាពក្នុងការបង្កើនថវិកាទៅដល់សាលារៀន និងគ្រឹះស្ថាន ទៅនឹងការបំពេញការងារ ដោយគិតទាំងវិធានការថ្មីស្ដីពីគុណភាព និងប្រសិទ្ធភាព<br><br>• សិក្សាវាយតំលៃពីប្រសិទ្ធភាព នៃយន្តការបែងចែកថវិកា និងលទ្ធភាពនៃការដាក់បញ្ចូលទៅជាយន្តការគ្រោងថវិកាសំរាប់កម្មវិធី នៅក្រោមកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ | • សិក្សាផលប៉ះពាល់រួមនៃកម្មវិធី លើការចូលរៀន គុណភាព និងប្រសិទ្ធភាពនៃការបំពេញការងាររបស់សាលារៀន និងរបស់គ្រឹះស្ថាន ។ |

| | | | |
|---|---|---|---|
| គ-ធានាចីរភាពនៃកំណែទំរង់កម្មវិធីសិក្សា និងការផ្តល់សៀវភៅសិក្សា | • បញ្ចប់ការកសាងគោលការណ៍នៃក្របខ័ណ្ឌកម្មវិធីសិក្សា ដោយគិតទាំងម៉ោងបង្រៀនទាំងនៅក្នុង និងក្រៅសាលា<br><br>• ពិនិត្យឡើងវិញយន្តការផ្តល់ហិរញ្ញប្បទាន និង ការផ្តល់សៀវភៅសិក្សា ដោយគិតទាំងការកែលំអស្ថានភាពនៃគ្រឹះស្ថានបោះពុម្ភ និងចែកផ្សាយ<br><br>• កិច្ចព្រមព្រៀងលើវិធានការបណ្តោះអាសន្ន ចំពោះការផ្តល់ហិរញ្ញប្បទាន សំរាប់សៀវភៅសិក្សា ដោយគិតទាំងការរួមចំណែករបស់រដ្ឋាភិបាល ។ | • បញ្ចប់ការគ្រោងជាសេចក្តីលំអិតនូវ ក្របខ័ណ្ឌកម្មវិធីសិក្សារយៈពេលវែង ដែលបានរៀបចំឡើងដើម្បីធានាការអនុវត្តគោលនយោបាយ របស់ផែនការយុទ្ធសាស្រ្តវិស័យអប់រំ បានទូលំទូលាយ រួមទាំងផែនការអភិវឌ្ឍកម្មវិធីសិក្សាសំរាប់ពេលខាងមុខ<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៍ នៃសៀវភៅសិក្សាដែលមានហើយជាផ្នែកមួយនៃយុទ្ធសាស្រ្តរយៈពេលវែង សំរាប់ធ្វើអោយទៅជាលក្ខណៈពាណិជ្ជកម្មទីផ្សារ ក្នុងការបោះ-ពុម្ពសៀវភៅសិក្សា ព្រមទាំងតួនាទីរបស់គ្រឹះស្ថានបោះពុម្ភ និងចែកផ្សាយ ។ | • ពិនិត្យលើផលប៉ះពាល់ នៃយុទ្ធសាស្រ្តផ្តល់សៀវភៅសិក្សា ទៅនឹងគុណភាព និងស្តង់ដានៃការអប់រំមូលដ្ឋាន<br><br>• អនុវត្តនូវយុទ្ធសាស្រ្តរយៈពេលវែង ចំពោះការបង្កើនអោយមានការប្រកួតប្រជែង នៅលើទីផ្សារបោះពុម្ភ ដែលនឹងអាចជាអ្នកផ្តល់សេវាឯកជន ក្នុងការអភិវឌ្ឍសៀវភៅសិក្សា។ |
| ឃ- បង្កើនសមធម៌ និងប្រសិទ្ធភាព ក្នុងការអភិវឌ្ឍការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន | • បញ្ចប់ការកែលំអយុទ្ធសាស្រ្ត នៃការផ្គត់ផ្គង់/តំរូវការគ្រូបង្រៀន ដោយគិតទាំងការកែលំអតួនាទីរបស់សាលាគរុកោសល្យ និងវិធានការដើម្បីកែលំអបុគ្គលិក នៅសាលា គរុកោសល្យ និងប្រសិទ្ធភាពរបស់សំភារៈបរិក្ខារ<br><br>• កែលំអផែនការបណ្តុះបណ្តាល និងពង្រាយគ្រូឡើងវិញទៅតាមសាលាដែលជួបការលំបាក តំបន់ព្រំដែន ជនជាតិភាគតិច គិតទាំងយុទ្ធសាស្រ្តកំណត់បុស្តិ៍ និងប្រាក់លើកទឹកចិត្ត | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៃកម្មវិធីដែលបានកែលំអ ដោយគិតទាំងផលពាក់ព័ន្ធនៃការពង្រាយបុគ្គលិក<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៍ នៃការបណ្តុះបណ្តាលគ្រូ និងពង្រាយគ្រូទៅតំបន់ជួបការលំបាក និងដាច់ស្រយាល | • សិក្សាពីផលប៉ះពាល់ នៃកម្មវិធីដែលបានកែលំអ រួមទាំងផលពាក់ព័ន្ធនៃការពង្រាយបុគ្គលិក<br><br>• សិក្សាពីផលប៉ះពាល់ ស្តីពីការបណ្តុះបណ្តាលគ្រូ និងការដាក់ពង្រាយគ្រូ ទៅតំបន់ជួបការលំបាក និងដាច់ស្រយាល |

| | | | |
|---|---|---|---|
| | • ផែនការសកម្មភាព សំរាប់ពង្រីកការធ្វើវិក្រិតការគ្រូបង្រៀន ដោយរួមបញ្ចូលទាំងការអភិវឌ្ឍសំភារៈរូបវ័ន្តដល់មជ្ឈមណ្ឌលធនធានសំរាប់បំប៉នគ្រូ និងផ្តល់សិទ្ធិអំណាចកាន់តែច្រើនទៅអោយខេត្ត សំរាប់កសាងផែនការវិក្រិតការគ្រូបង្រៀន ។ | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៃកម្មវិធីវិក្រិតការគ្រូបង្រៀន ដោយគិតទាំងផលប៉ះពាល់ទៅលើប្រសិទ្ធភាព និងតំរូវការសាលាគរុកោសល្យបន្ថែម នៅតាមខេត្តដែលមិនទាន់មាន។ | • សិក្សាពីផលប៉ះពាល់ លើកម្មវិធីវិក្រិតការគ្រូបង្រៀន រួមទាំងប្រសិទ្ធភាពការបង្រៀនរបស់គ្រូ។ |
| ង- ពង្រឹងប្រព័ន្ធវាយតំលៃការបំពេញការងារបុគ្គលិក និងសាលារៀន | • ផែនការសកម្មភាពសំរាប់ដាក់អោយដំណើរការនូវប្រព័ន្ធឯកភាពលើការបំពេញការងារ ប័ណ្ណរាយការណ៏របស់សាលា និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ដោយអនុវត្តនៅសាលាបឋមសិក្សាជាជំហានដំបូង<br><br>• ផែនការសកម្មភាព សំរាប់ប្រព័ន្ធវាយតំលៃការបំពេញការងារបុគ្គលិកនៅទូទាំងប្រទេស ក្នុងនោះអនុវត្តទៅលើនាយក និងគ្រូនៅសាលាបឋមសិក្សា ជាជំហានដំបូង។ | • ពិនិត្យឡើងវិញពីការវិវត្តន៍ នៅដំណាក់កាលដំបូងនៃការឯកភាពលើការបំពេញការងារ និង លើបទពិសោធដែលទទួលបាន សំរាប់ពេលក្រោយ<br><br>• ពិនិត្យឡើងវិញពីការវិវត្តន៍ នៅដំណាក់កាលដំបូងនៃប្រព័ន្ធវាយតំលៃការបំពេញការងាររបស់បុគ្គលិក និងបទពិសោធដែលទទួលបានសំរាប់ពេលក្រោយ។ | • ពិនិត្យឡើងវិញលើផលប៉ះពាល់ ទៅលើប្រព័ន្ធឯកភាពនៃការបំពេញការងារ និង ទៅលើបទពិសោធដែលទទួលបាន សំរាប់យុទ្ធសាស្ត្រនាពេលអនាគត<br><br>• ពិនិត្យឡើងវិញលើផលប៉ះពាល់ ស្តីពីប្រព័ន្ធវាយតំលៃការបំពេញការងារបុគ្គលិក និងទៅលើបទពិសោធដែលទទួលបាន សំរាប់យុទ្ធ-សាស្ត្រនាពេលអនាគត។ |
| ច- កែលំអ និងពង្រីកប្រព័ន្ធវាយតំលៃសមត្ថភាពសិក្សារបស់សិស្ស និងប្រព័ន្ធប្រលង នៅតាមសាលារៀន និងគ្រឹះស្ថានក្រោយមធ្យមសិក្សា | • កំណត់ស្តង់ដាអប្បបរមានៃការសិក្សារបស់សិស្ស ពីថ្នាក់ទី១-១២ និងផែនការសកម្មភាពសំរាប់សាកល្បងនៅតាមកំរិតថ្នាក់មួយចំនួននៅបឋមសិក្សា<br><br>• ផែនការសកម្មភាពសំរាប់កែលំអ ការប្រលងនៅថ្នាក់ទី៩ និងទី១២ និង ការវាយតំលៃស្តង់ដានៅគ្រឹះស្ថានឧត្តមសិក្សា និងTVET . | • អនុវត្តនូវតែសស្តង់ដានៅទូទាំងប្រទេសនៅតាមកំរិតថ្នាក់ដែលបានកំណត់ និងការកែលំអការប្រលងនៅថ្នាក់ទី ៩ និងទី១២ ដោយគិតទាំងការផ្សព្វផ្សាយជាសាធារណៈ<br><br>• ធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីស្តង់ដាគ្រឹះស្ថានសិក្សា TVET និងឧត្តមសិក្សា សាធារណៈ និងឯកជន ដោយគិតទាំង ទីកន្លែងដែលនិស្សិតទៅបំរើការ និង មុខរបររបស់ពួកគេ។ | • ពិនិត្យឡើងវិញលើនិន្នាការនៃគុណភាព និង ស្តង់ដា និងផែនការសកម្មភាពពេលខាងមុខ<br><br>• រាយការណ៏ទៅរដ្ឋសភា អំពីការវិវត្តន៍នៃការកែលំអស្តង់ដាអប់រំនៅគ្រប់កំរិត រួមទាំងតួនាទីរបស់ MoEYS ក្នុងការធានាគុណភាព<br>• ពិនិត្យឡើងវិញ ពីការវិវត្តន៍នៃកំណែទំរង់ស្ថាប័នក្រសួង អយក ចំពោះការពិនិត្យតាមដានស្តង់ដា។ |